**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ១៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សហគ្រាសធុនមីក្រូ តូច និងមធ្យម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍



ᨵᨶ

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :-**

ត្រូវបានបង្កើត "**គណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សហគ្រាសធុនមីក្រូ តូច និងមធ្យម**" សរសេរជាអក្សរកាត់ថា "**គ.ម.ត.ម.**" នៅក្រោមឆត្រនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២ :-**

**គ.ម.ត.ម.** មានភារកិច្ច ដូចខាងក្រោម៖

- អនុម័តសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០
- ដឹកនាំ, សម្របសម្រួល និងដោះស្រាយបញ្ហារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរស្ថាប័ន ដើម្បីអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនូវកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍលើការងារជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម នៅកម្ពុជា
- ដឹកនាំ រៀបចំ និងស្នើឡើងសកម្មភាពគោលនយោបាយ និងយុទ្ធសាស្ត្រ ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីបន្តលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម តាមតម្រូវការចាំបាច់
- សម្របសម្រួលក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០ ដោយផ្អែកលើគោលដៅ និងសូចនាករដែលបានកំណត់ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំវិធានការចាំបាច់ក្នុងការដោះស្រាយបញ្ហាចំពោះមុខ ដែលកើតឡើងក្នុងពេលអនុវត្ត
- ពិនិត្យ និងរៀបចំជម្រើសគោលនយោបាយ និងយុទ្ធសាស្ត្រ សម្រាប់ដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យមក្នុងដំណាក់កាលបន្ទាប់
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី២
## សមាសភាព និងរចនាសម្ព័ន្ធ

**មាត្រា៣ :_**

**គ.ម.គ.ម.** មានសមាសភាព ដូចតទៅ៖

| | |
|---|---|
| ១- ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកមួយរូប | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧- ទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៨- អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២០- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២១- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២២- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២៣- អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៤- អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ | សមាជិក |

២៥- អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល — សមាជិក
២៦- អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម — សមាជិក
២៧- អគ្គនាយកធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា — សមាជិក
២៨- អគ្គនាយកសាជីវកម្មធានាឥណទានកម្ពុជា — សមាជិក
២៩- នាយកប្រតិបត្តិនៃសហគ្រិនខ្មែរ — សមាជិក
៣០- នាយកប្រតិបត្តិមូលនិធិអភិវឌ្ឍន៍ជំនាញ — សមាជិក
៣១- អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត — សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ម.គ.ម.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា៤ :_**

**គ.ម.គ.ម.** អាចមានអនុគណៈកម្មាធិការ ឬ ក្រុមការងារបច្ចេកទេសផ្សេងៗ ដើម្បីបម្រើការងារក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា២ ខាងលើ តាមតម្រូវការចាំបាច់។ អនុគណៈកម្មាធិការ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន **គ.ម.គ.ម.**។ ក្រុមការងារបច្ចេកទេសរបស់ **គ.ម.គ.ម.** ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ម.គ.ម.**។

## ជំពូកទី៣
## ការប្រព្រឹត្តទៅនៃ គ.ម.គ.ម.

**មាត្រា៥ :_**

**គ.ម.គ.ម.** រៀបចំកិច្ចប្រជុំរៀងរាល់មួយឆ្នាំម្តងយ៉ាងតិច ដើម្បីពិនិត្យលើស្ថានភាព វឌ្ឍនភាព និងបញ្ហាប្រឈមផ្សេងៗ ពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រជាតិ និងបញ្ហាពាក់ព័ន្ធផ្សេងៗ និងគោរពរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តាមការអញ្ជើញរបស់ប្រធាន, អនុប្រធាន និងសមាជិក **គ.ម.គ.ម.** ត្រូវចូលរួមប្រជុំ។ ក្នុងករណីអវត្តមាន ឬ មានធុរៈ, អនុប្រធាន និងសមាជិក **គ.ម.គ.ម.** ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា៦ :_**

**គ.ម.គ.ម.** អាចស្នើសុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយសម្របសម្រួលដឹកនាំ និងលើកជាអនុសាសន៍គោលនយោបាយបន្ថែម ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។



96

**មាត្រា៧ :-**

ប្រធាន **គ.ម.ត.ម.** មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងរបស់ប្រធានស្ថាប័ន ឬ អាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៨ :-**

**គ.ម.ត.ម.** ព្រមទាំងអនុគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍ, តំណាងវិស័យឯកជន, តំណាងសង្គមស៊ីវិល, ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក, អ្នកសង្កេតការណ៍ ឬ អ្នកផ្តល់យោបល់ តាមការចាំបាច់។

**មាត្រា៩ :-**

**គ.ម.ត.ម.** មានលេខាធិការដ្ឋានមួយ ដែលជាសេនាធិការក្នុងការងារសម្របសម្រួលរួម លើការអនុវត្តយុទ្ធសាស្ត្រនេះ និងការងារពាក់ព័ន្ធផ្សេងៗ។

លេខាធិការដ្ឋាន ដឹកនាំដោយប្រធានមួយរូប ដែលមានសមាសភាពជា រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមានអនុប្រធានចំនួន ៣ រូប ដែលមានសមាសភាពជា រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ជាសមាជិក។ សមាសភាព តួនាទី និងភារកិច្ច នៃលេខាធិការដ្ឋាននៃ **គ.ម.ត.ម.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ម.ត.ម.**។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា១០ :-**

**គ.ម.ត.ម.** និងរចនាសម្ព័ន្ធក្រោមឱវាទ អាចប្រើប្រាស់ថវិកាជាតិ ឬ ប្រភពថវិកាស្របច្បាប់ផ្សេងៗ តាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន ។

អនុគណៈកម្មាធិការ, ក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋាន ក្រោមឱវាទ **គ.ម.ត.ម.** ប្រើប្រាស់ប្រភពធនធានថវិកានៅក្នុងក្របខ័ណ្ឌថវិការបស់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចដឹកនាំ អនុគណៈកម្មាធិការ, ក្រុមការងារបច្ចេកទេសនីមួយៗ និងលេខាធិការដ្ឋាន។

**គ.ម.ត.ម.** អនុគណៈកម្មាធិការ, ក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋាន ក្រោមឱវាទ **គ.ម.ត.ម.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិពីប្រភពផ្សេងៗស្របច្បាប់ សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។



ម

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ :_**

អនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ :_**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០២៦
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ